**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ព្រះរាជក្រម

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- យោងតាមព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពី សម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និង អំពីរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

# ប្រកាសឱ្យប្រើ

ច្បាប់ដែលបានអនុម័តដោយរដ្ឋសភា នៅថ្ងៃទី ១៦ ខែឧសភា ឆ្នាំ ១៩៩៥ ស្តីពីសភាពាណិជ្ជកម្មដែលមានសេចក្តីទាំងស្រុងដូចតទៅ:

## ជំពូកទី ១
## ការរៀបចំនិងការប្រព្រឹត្តទៅនៃសភាពាណិជ្ជកម្ម

**មាត្រា ១ :**

សភាពាណិជ្ជកម្ម គឺជាគ្រឹះស្ថានសាធារណៈនៅក្រោមអាណាព្យាបាលនៃក្រសួងពាណិជ្ជកម្មដែលធ្វើសកម្មភាព ដើម្បីជាផលប្រយោជន៍ខាងវិស័យពាណិជ្ជកម្ម ឧស្សាហកម្ម កសិកម្ម សិប្បកម្ម និងសេវាកម្មក្នុងមណ្ឌលរបស់ខ្លួន ។

នៅតាមខេត្ត ក្រុងនិមួយៗមានសភាពាណិជ្ជកម្មមួយ ។ ប៉ុន្តែមណ្ឌលនៃសភាពាណិជ្ជកម្មមួយអាចលាតសន្ធឹងទៅខេត្តក្រុង ច្រើនបានកាលណាស្ថានការណ៍សេដ្ឋកិច្ចតម្រូវឱ្យធ្វើដូច្នេះ ។

**មាត្រា ២ :**

សភាពាណិជ្ជកម្មនៅតាមខេត្ត ក្រុងនីមួយៗ ត្រូវបង្កើតឡើងដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងពាណិជ្ជកម្ម ។ ព្រំដែនមណ្ឌលនៃសភាពាណិជ្ជកម្មទីមួយៗត្រូវកំណត់ឡើងដោយអនុក្រឹត្យដែលបង្កើតសភានោះ ។

**មាត្រា ៣ :**

សភាពាណិជ្ជកម្មនិមួយៗ ត្រូវគ្រប់គ្រងដោយការិយាល័យមួយដឹកនាំដោយប្រធានមួយរូប និង អនុប្រធានមួយរូបឬច្រើនរូប ។

ចំនួនសមាជិកនៃការិយាល័យ ទម្រង់បែបបទនៃការជ្រើសតាំងប្រធានព្រមទាំងការប្រព្រឹត្តទៅនៃការិយាល័យនេះ ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុង របស់សភាពាណិជ្ជកម្មដែលមានទម្រង់ដូចគ្នាតែមួយសំរាប់ សភាពាណិជ្ជកម្មទូទៅនិងមានការយល់ព្រមពីគណៈរដ្ឋមន្ត្រី តាមសំណើរបស់ក្រសួងពាណិជ្ជកម្ម ។

**មាត្រា ៤ :**

សភាពាណិជ្ជកម្មមានសមាជិកសញ្ជាតិជាខ្មែរ ត្រូវបានជ្រើសតាំងដោយការបោះឆ្នោត ។ អាណត្តិ ចំនួនសមាជិក របៀបរបប និងការរៀបចំការបោះឆ្នោតត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៥ :**

នៅអមសមាជិកជ្រើសតាំង ដោយការបោះឆ្នោតសភាពាណិជ្ជកម្មមានសមាជិកទីប្រឹក្សា មួយចំនួនទៀត ដែលចូលរួមក្នុងការពិភាក្សាតែមានភារកិច្ចត្រឹមតែជាអ្នកផ្តល់មតិប៉ុណ្ណោះ ។

ចំនួននៃទីប្រឹក្សា មិនអាចលើសពីចំនួនសមាជិកជ្រើសតាំងដោយការបោះឆ្នោតឡើយ។ ទីប្រឹក្សាទាំងនេះត្រូវបានតែងតាំងនៅពេលផ្លាស់សភាជាថ្មីម្តងៗ ។ ទីប្រឹក្សាត្រូវជ្រើសរើសក្នុងចំណោម :

១- តំណាងអង្គការ ឬតំណាងសមាគម ម្ចាស់សហគ្រាសពាណិជ្ជកម្ម ឧស្សាហកម្ម កសិកម្ម សិប្បកម្ម និងសេវាកម្ម ។

២- តំណាងក្រុមប្រឹក្សាដឹកនាំនៃសហគ្រាសពាណិជ្ជកម្ម ឧស្សាហកម្ម កសិកម្ម សិប្បកម្ម និងសេវាកម្ម ។

៣- តំណាងបុគ្គលិកនៃសហគ្រាសពាណិជ្ជកម្ម ឧស្សាហកម្ម កសិកម្ម សិប្បកម្ម និង សេវាកម្ម ។

ក្រសួងពាណិជ្ជកម្មកំណត់តាមប្រកាស បន្ទាប់ពីបានទទួលសេចក្តីស្នើពីសភាពាណិជ្ជកម្មនូវ :

- ចំនួនទីប្រឹក្សា
- ចំនួនសមាជិកប្រភេទនីមួយៗ ដូចមានចែងខាងលើនេះ
- បញ្ជីនៃអង្គការ ឬ នៃសមាគម ដែលមានសិទ្ធិចាត់តាំងតំណាងទីប្រឹក្សា ។

**មាត្រា ៦ :**

អភិបាលខេត្ត ក្រុង ឬតំណាង និងតំណាងក្រសួងពាណិជ្ជកម្មមានសិទ្ធិចូលរួមក្នុងសម័យប្រជុំសភាពាណិជ្ជកម្ម តែមានភារកិច្ចត្រឹមតែជាអ្នកផ្តល់មតិប៉ុណ្ណោះ ។

**មាត្រា ៧ :**

សមាជិកជ្រើសតាំងនិងទីប្រឹក្សានៃសភាពាណិជ្ជកម្ម បំពេញមុខងាររបស់ខ្លួនដោយមិនយកប្រាក់ខែឬប្រាក់បំណាច់អ្វីឡើយ ។

**មាត្រា ៨ :**

សភាពាណិជ្ជកម្មទាំងឡាយអាចសហការគ្នា តាមរយៈប្រធានរបស់ខ្លួនក្នុងក្របខ័ណ្ឌនៃភារកិច្ច ស្តីពីបញ្ហាទាំងឡាយដែលពាក់ព័ន្ធទៅនឹងមណ្ឌលរៀង១ខ្លួន ។

## ជំពូកទី ២
## ភារកិច្ចរបស់សភាពាណិជ្ជកម្ម

**មាត្រា ៩ :**

សភាពាណិជ្ជកម្មមានភារកិច្ចដូចតទៅ :

១- ធ្វើទំនាក់ទំនងជាមួយនិងប្រភពសេដ្ឋកិច្ចក្នុងប្រទេស និងក្រៅប្រទេសដើម្បីស្រង់យកពត៌មានដែលពាក់ព័ន្ធ នឹងកិច្ចអភិវឌ្ឍន៍សហគ្រាសជាតិ

២- បង្កើនប្រសិទ្ធភាព សហគ្រាសទាំងឡាយ ដើម្បីជាផលប្រយោជន៍ខាងវិស័យពាណិជ្ជកម្ម ឧស្សាហកម្ម កសិកម្ម សិប្បកម្ម និងសេដ្ឋកិច្ចទូទៅ ដូចជាការរៀបចំផ្សព្វផ្សាយនូវស្ថិតិពាណិជ្ជកម្ម និងសេដ្ឋកិច្ច ការសិក្សាស្រាវជ្រាវពិចារណាលើបញ្ហាសេដ្ឋកិច្ច និងពាណិជ្ជកម្មការលើកតំកើងផ្នែកទេសចរណ៍។

៣- ផ្តល់ជូនរាជរដ្ឋាភិបាលនិងអាជ្ញាធរខេត្ត ក្រុង នូវយោបល់និងពត៌មានទាំងឡាយស្តីពីបញ្ហាពាណិជ្ជកម្ម ឧស្សាហកម្ម កសិកម្ម សិប្បកម្ម និងសេវាកម្ម ។

៤- ដើរតួជាអ្នកតំណាងសមាគមន៍ពាណិជ្ជកម្ម ឧស្សាហកម្ម កសិកម្ម សិប្បកម្ម និងសេវាកម្ម សំរាប់សំរបសំរួលកិច្ចការជាមួយរដ្ឋអំណាច ។

៥- ធានារ៉ាប់រងនូវការគ្រប់គ្រងសេវា ធានា និង អនុវត្តការងារចាំបាច់ដែលជាផលប្រយោជន៍ក្នុងសមត្ថកិច្ចរបស់ខ្លួន ។

៦- ដើរតួជាអាជ្ញាកណ្តាលក្នុងការដោះស្រាយវិវាទពាណិជ្ជកម្ម ។

**មាត្រា ១០ :**

សភាពាណិជ្ជកម្មត្រូវផ្តល់យោបល់ :

១- អំពីគំរោងបទបញ្ជាទាំងឡាយផ្នែកសេដ្ឋកិច្ច និងពាណិជ្ជកម្ម ។

២- អំពីតម្លៃ និង អាករលើសេវាទាំងឡាយដែលរដ្ឋធ្វើសម្បទានអោយសហគ្រាសណាមួយ ។

៣- អំពីផលប្រយោជន៍ នៃគំរោងសំណង់សាធារណៈការ ដែលត្រូវអនុវត្តក្នុងមណ្ឌលនិមួយៗព្រមទាំងពន្ធអាករ ដែលត្រូវប្រមូលយកពីអ្នកប្រើប្រាស់ដើម្បីកសាងសំណង់នោះ ។

៤- អំពីគំរោងវិសោធនកម្មច្បាប់ វិស័យគយ ពាណិជ្ជកម្ម និងសេដ្ឋកិច្ច ។

៥- អំពីការកំណត់អត្រាពន្ធគយ ។

ម្យ៉ាងទៀត តាមគំនិតផ្តួចផ្តើមផ្ទាល់របស់ខ្លួន សភាពាណិជ្ជកម្មអាចធ្វើសំណូមពរទាំងឡាយដែលទាក់ទង នឹងសកម្មភាពពាណិជ្ជកម្ម ឧស្សាហកម្ម កសិកម្ម សិប្បកម្ម និងសេវាកម្ម ។

**មាត្រា ១១ :**

តាមសំណូមពរម្ចាស់អំណោយឯកជន ឬរដ្ឋ ព្រមទាំងមានការយល់ព្រមពីគណៈរដ្ឋមន្ត្រី តាមសំណើរបស់ក្រសួងពាណិជ្ជកម្ម សភាពាណិជ្ជកម្មអាចបង្កើត ឬគ្រប់គ្រងគ្រឹះស្ថានពាណិជ្ជកម្ម ឧស្សាហកម្ម កសិកម្ម សិប្បកម្ម និងសេវាកម្ម ទោះជារបស់រដ្ឋក្តី របស់ឯកជនក្តី ដូចជាឃ្លាំងផ្ទុកទំនិញ សាលលក់ឥវ៉ាន់ ភណ្ឌាគារ ពិព័រណ៍អចិន្ត្រៃយ៍ សារមន្ទីរពាណិជ្ជកម្ម សាលបណ្តុះបណ្តាលវិជ្ជាជីវៈ ពាណិជ្ជកម្ម និង ឧស្សាហកម្ម ទីផ្សារសាធារណៈ មហាសាលសំរាប់ទេសចរណ៍ ។

**មាត្រា ១២ :**

សភាពាណិជ្ជកម្មអាចទិញ ឬសង់អាគារសំរាប់ប្រើប្រាស់ជារបស់ខ្លួនផ្ទាល់ឬសំរាប់ជួលធ្វើអាជីវកម្ម បើគ្មានការជំទាស់ពីគណៈរដ្ឋមន្ត្រីតាមសំណើរបស់ក្រសួងពាណិជ្ជកម្ម ។

**មាត្រា ១៣ :**

ដោយមានសេចក្តីសំរេចរបស់គណៈរដ្ឋមន្ត្រី តាមសំណើរបស់ក្រសួងពាណិជ្ជកម្ម សភាពាណិជ្ជកម្មអាចចូលរួមក្នុងការដេញថ្លៃជាសាធារណៈ ដើម្បីទទួលភារៈជាសម្បទានិកនៃសំណង់សាធារណៈការទាំងឡាយ ឬ ទទួលបន្ទុកធ្វើសេវាសាធារណៈ ។

**មាត្រា ១៤ :**

រៀងរាល់ឆ្នាំ សភាពាណិជ្ជកម្មត្រូវបញ្ជូនរបាយការណ៍ទូទៅមួយ ស្តីពី

សកម្មភាពរបស់ខ្លួនទៅក្រសួងពាណិជ្ជកម្ម ដែលមានកាតព្វកិច្ចផ្សព្វផ្សាយជាសាធារណៈនូវរបាយការណ៍នោះ ។

## ជំពូកទី ៣
## ហិរញ្ញប្បទាន

**មាត្រា ១៥ :**

ចំណាយសំរាប់ការប្រព្រឹត្តទៅនៃសភាពាណិជ្ជកម្ម ត្រូវផ្គត់ផ្គង់ដោយភាគទានប្រចាំឆ្នាំរបស់សមាជិក បូករួមជាមួយនិងចំណូល ព្រមទាំងវិភាគទានមកពីប្រភពផ្សេងៗទៀត ។

**មាត្រា ១៦ :**

បើគ្មានការជំទាស់ពីក្រសួងពាណិជ្ជកម្ម សភាពាណិជ្ជកម្មអាចខ្ចីប្រាក់ដើម្បីរ៉ាប់រងចំណាយនានាគ្រប់វិស័យដែលពាក់ព័ន្ធ និងភារកិច្ចបន្ថែមរបស់ខ្លួន ដែលមានចែងក្នុងមាត្រា ១៥ នៃច្បាប់នេះ ។

**មាត្រា ១៧ :**

សំណងបំណុលទាំងដើមទាំងការ ដែលសភាពាណិជ្ជកម្មបានខ្ចី ត្រូវធានារ៉ាប់រងដោយប្រាក់ចំណូលនៃអាជីវកម្ម ។

**មាត្រា ១៨ :**

បើគ្មានការជំទាស់ពីក្រសួងពាណិជ្ជកម្ម សភាពាណិជ្ជកម្មមួយចំនួន

អាចនឹងខ្ចីឥណទានរួម ដើម្បីយកមកបង្កើត ផ្គត់ផ្គង់គ្រឹះស្ថានសេវា ឬ សំណង់ដែលជាប្រយោជន៍រួមរបស់សភាពាណិជ្ជកម្មទាំងនោះ ។ សំណង់បំណុលនេះត្រូវរ៉ាប់រងដោយប្រាក់ចំណូលរួមនៃអាជីវកម្ម ។

**មាត្រា ១៩ :**

ការខ្ចីប្រាក់ដូចមានចែងក្នុងមាត្រា ១៦ ១៧ និង១៨ ខាងលើនេះ អាចធ្វើតាមរយៈ ធនាគារណាដែលផ្តល់អត្ថប្រយោជន៍ប្រសើរជាងគេ ។

**មាត្រា ២០ :**

ក្រៅពីថវិកាសាមញ្ញ សភាពាណិជ្ជកម្មរៀបចំនូវថវិកាពិសេស សំរាប់គ្រឹះស្ថានពាណិជ្ជកម្ម ឧស្សាហកម្ម កសិកម្ម និងសិប្បកម្មដែលខ្លួនគ្រប់គ្រង ។

ក្នុងរយៈពេល ៦ ខែដំបូងនៃឆ្នាំនិមួយៗ សភាពាណិជ្ជកម្មត្រូវផ្ញើជូនក្រសួងពាណិជ្ជកម្ម ដើម្បីសុំការយល់ព្រមលើរបាយការណ៍ស្តីពីចំណូលនិង ចំណាយនៃឆ្នាំមុនហើយនិងគំរោងថវិកាចំណូលចំណាយនៃឆ្នាំបន្ទាប់ដោយមានឯកសារគណនេយ្យភ្ជាប់ជាមួយផង ។

ម្យ៉ាងទៀតសភាពាណិជ្ជកម្ម ត្រូវផ្ញើតារាងរំលោះប្រាក់ខ្ចីជូនទៅក្រសួងពាណិជ្ជកម្មជារៀងរាល់ឆ្នាំ ។

សភាពាណិជ្ជកម្មអាចបំរុងទុកទឹកប្រាក់ទាំងអស់ ឬមួយភាគនៃចំណូលលើស ដែលបានពីការគ្រប់គ្រងសេវាធម្មតាសំរាប់បង្កើតមូលនិធិពិសេស មួយដើម្បីផ្គត់ផ្គង់ចំណាយជាបន្ទាន់ដែលមិនបានគ្រោងទុក ។ ទោះក្នុងករណីណាក្តី ចំនួនមូលនិធិបំរុងនេះមិនអាច

ខ្ពស់ជាង២០ភាគរយនៃធនធានប្រចាំឆ្នាំរបស់ថវិកានោះបានឡើយ ។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

**មាត្រា ២១ :**

បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២២ :**

ច្បាប់នេះត្រូវប្រកាសទុកជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៩៩៥

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

បានយកសេចក្តីប្រកាបបង្គំទូលថ្វាយ

បានបង្គំទូលថ្វាយនិងជំរាបជូន សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

សម្តេចនាយករដ្ឋមន្ត្រីទី ១និងទី ២ **នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី២**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ព្រះហស្តលេខា ហត្ថលេខា**

**ហត្ថលេខា នរោត្តម រណឫទ្ធិ ហ៊ុន សែន**

**ចម ប្រសិទ្ធ** លេខៈ .....៣៣...ច.ល

ដើម្បីចម្លងចែក

ភ្នំពេញ. ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ១៩៩៤

អគ្គលេខាធិការរងរាជធានីភ្នំពេញ

ស៊ុន សីរី

# អនុក្រឹត្យ

# ស្តីពី

# របៀបរបប និង

# ការរៀបចំការបោះឆ្នោតសភាពាណិជ្ជកម្ម

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ៤២ អនក្រ.បក

**<u>អនុក្រឹត្យ</u>**

**ស្តីពី**

**របៀបរបប និង ការរៀបចំការបោះឆ្នោតសភាពាណិជ្ជកម្ម**

**<u>រាជរដ្ឋាភិបាល</u>**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៥/០៣ ចុះ

ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសភាពាណិជ្ជកម្ម

- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សំរេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ :**

សភាពាណិជ្ជកម្ម មានសមាជិកជ្រើសតាំងតាមការបោះឆ្នោត និងសមាជិកទីប្រឹក្សា ។ សមាជិកជ្រើសតាំងតាមការបោះឆ្នោតត្រូវបានកំណត់ដោយអនុក្រឹត្យបង្កើតសភាពាណិជ្ជកម្មនិមួយៗ ហើយចំនួនសមាជិកទីប្រឹក្សាត្រូវកំណត់ដោយប្រកាសរបស់ក្រសួងពាណិជ្ជកម្ម។ អាណត្តិរបស់សមាជិកសភាពាណិជ្ជកម្មមានរយៈពេល ០៦ ឆ្នាំ ។ រៀងរាល់ ០៣ឆ្នាំម្ដង សភាពាណិជ្ជកម្មត្រូវរៀបចំការបោះឆ្នោតជ្រើសរើសសមាជិកជ្រើសតាំងថ្មីចំនួនពាក់កណ្ដាល លើកលែងតែនៅក្នុងអាណត្តិដំបូង ត្រូវមានការចាប់ឆ្នោតជ្រើសរើសសមាជិកចំនួនពាក់កណ្ដាល ដែលត្រូវបញ្ចប់អាណត្តិ ក្រោយរយៈពេល ០៣ ឆ្នាំ ។

**មាត្រា ២ :**

សមាជិកជ្រើសតាំងនៃសភាពាណិជ្ជកម្ម ត្រូវចូលបំពេញការងាររបស់ខ្លួនក្រោយថ្ងៃប្រកាសលទ្ធផលបោះឆ្នោតយ៉ាងយូរមួយខែ ក្រោមអធិបតីភាពរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ឬតំណាង និង អភិបាលខេត្ត-ក្រុង ឬ តំណាងនៃមណ្ឌលរបស់សាមីសភាពាណិជ្ជកម្ម ។

**មាត្រា ៣ :**

ក្នុងករណីដែលចំនួនសមាជិកជ្រើសតាំង ធ្លាក់មកនៅទាបជាងពាក់កណ្តាល សភាពាណិជ្ជកម្មត្រូវបានរំសាយ ដោយអនុក្រឹតតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។ ការជ្រើសតាំងសមាជិកជាថ្មី ត្រូវធ្វើក្នុងរយៈពេល ០៣ ខែយ៉ាងយូរគិតពីថ្ងៃចេញអនុក្រឹត្យ ។

ក្រសួងពាណិជ្ជកម្មត្រូវប្រកាសតែងតាំងគណៈកម្មការបណ្តោះអាសន្នមួយ ដើម្បីដឹកនាំសភាពាណិជ្ជកម្មជាបន្ទាន់ ។

## ជំពូកទី ២

## គណៈកម្មាការរៀបចំការបោះឆ្នោត

**មាត្រា ៤ :**

ក/- គណៈកម្មាការរៀបចំការបោះឆ្នោត ជ្រើសរើសសមាជិកជ្រើសតាំងសភាពាណិជ្ជកម្ម អាណត្តិទី១ មានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| - តំណាងក្រសួងពាណិជ្ជកម្ម | ប្រធាន |
| - តំណាងក្រុមប្រឹក្សាអ្នកច្បាប់ | អនុប្រធាន |
| - តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| - តំណាងក្រសួងមហាផ្ទៃ | សមាជិក |
| - តំណាងសាលាខេត្ត-ក្រុង សាមី | សមាជិក |
| - តំណាងក្រសួងទេសចរណ៍ | សមាជិក |
| - តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| - តំណាងធនាគារជាតិនៃកម្ពុជា | សមាជិក |
| - តំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| - តំណាងក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| - តំណាងក្រសួងប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| - តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| - តំណាងក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| - តំណាងក្រសួងយុត្តិធម៌ | សមាជិក |
| - មន្ត្រីក្រសួងពាណិជ្ជកម្ម ០២ រូប | លេខាធិការ |

ខ/- គណៈកម្មាការរៀបចំការឆ្នោតជ្រើសរើសសមាជិកជ្រើសតាំងសភាពាណិជ្ជកម្មអាណត្តិបន្តបន្ទាប់ មានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| - តំណាងក្រសួងពាណិជ្ជកម្ម | ប្រធាន |
| - តំណាងសាមីសភាពាណិជ្ជកម្ម | អនុប្រធាន |
| - តំណាងក្រសួងមហាផ្ទៃ | សមាជិក |
| - តំណាងសាលាខេត្ត-ក្រុង សាមី | សមាជិក |
| - អគ្គនាយកសាមីសភាពាណិជ្ជកម្ម | លេខាធិការ |

**មាត្រា ៥ :**

គណៈកម្មាការរៀបចំការបោះឆ្នោត មានភារកិច្ចដូចតទៅ :

- ណែនាំលំអិត ស្តីពីបែបបទបោះឆ្នោត ដល់សាធារណជន
- ធ្វើបញ្ជីអ្នកមានសិទ្ធិបោះឆ្នោត តាមប្រភេទអាជីវកម្មនិមួយៗ ប្រភេទពាណិជ្ជកម្ម ប្រភេទឧស្សាហកម្ម និងសិប្បកម្ម ប្រភេទសេវាកម្មនិងវិជ្ជាជីវៈសេរី ប្រភេទកសិកម្ម ។ បញ្ជីនេះត្រូវចុះហត្ថលេខាបញ្ជាក់ដោយរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។
- ធ្វើប័ណ្ណគ្រប់ជំពូកសំរាប់ការបោះឆ្នោត
- ធ្វើបញ្ជីបេក្ខជនឈរឈ្មោះជាសមាជិកជ្រើសតាំង របស់សភាពាណិជ្ជកម្ម។ បញ្ជីនេះត្រូវចុះហត្ថលេខាបញ្ជាក់ដោយ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។
- ចាត់វាលវិធានការណ៍សំរាប់ត្រួតពិនិត្យមើលការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។
- រៀបចំការិយាល័យបោះឆ្នោត ។
- ដើម្បីបំពេញកាតព្វកិច្ចរបស់ខ្លួន ឱ្យមានប្រសិទ្ធិភាពគណៈកម្មាការរៀបចំការបោះឆ្នោត មានសិទ្ធិលប់ឈ្មោះបេក្ខជនណាមួយចេញពីបញ្ជីបេក្ខជន ក្នុងករណីដែលសាមីខ្លួនមិនគោរពបែបបទ និងការណែនាំរបស់គណៈកម្មការក្នុងការបោះឆ្នោត ។

**មាត្រា ៦ :**

ក្រសួងពាណិជ្ជកម្មត្រូវធ្វើការកំណត់ទីតាំងរបស់គណៈកម្មាការសំរាប់ការបោះឆ្នោតនៅអាណត្តិទី ១។ ចំពោះការបោះឆ្នោតសំរាប់អាណត្តិ

បន្តបន្ទាប់ទៀត ទីតាំងសំរាប់គណៈកម្មាការនេះត្រូវកំណត់ដោយសាមីសភាពាណិជ្ជកម្ម ។

សមាជិកគណៈកម្មាការត្រូវចូលរួមប្រជុំ និងបំពេញការងារតាមការកំណត់របស់ប្រធាន ។

សេចក្តីសំរេចរបស់គណៈកម្មាការ និងមានសុពលភាពបាន លុះណាតែមានសមាជិកចំនួនពាក់កណ្តាលយ៉ាងតិចមកចូលរួមប្រជុំ ។

**<u>មាត្រា ៧</u> :**

រាល់ការចំណាយរបស់គណៈកម្មាការក្នុងការរៀបចំការបោះឆ្នោតនៅអាណត្តិទី ១នេះជាបន្ទុករបស់ថវិការដ្ឋ។ ការចំណាយសំរាប់ការបោះឆ្នោតនៅអាណត្តិបន្តបន្ទាប់ទៀត ជាបន្ទុករបស់សាមីសភាពាណិជ្ជកម្ម ។

## ជំពូកទី ៣

## ការបោះឆ្នោត

**<u>មាត្រា ៨</u> :**

ក/- អ្នកមានសិទ្ធិបោះឆ្នោតជ្រើសតាំងសភាពាណិជ្ជកម្មអាណត្តិទី ១ ត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម :

១- មានសញ្ជាតិជាខ្មែរ

២- មានអាយុយ៉ាងតិច ១៨ ឆ្នាំ

3- ជាពាណិជ្ជករ ឧស្សាហករ សិប្បករ អ្នកធ្វើសេវាទេសចរណ៍

អ្នកធ្វើអាជីវកម្មកសិកម្ម អ្នកធ្វើសេវាកម្មផ្សេងៗទៀត សហគ្រាស និងក្រុមហ៊ុននានាដែលបានចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម ឬបានទទួលការអនុញ្ញាតពីក្រសួង ស្ថាប័នមានសមត្ថកិច្ចណាមួយ ឱ្យធ្វើអាជីវកម្ម ហើយដែលមានទីស្នាក់ការ ឬអាគារធ្វើអាជីវកម្មនៅតាមខេត្ត-ក្រុងសាមី ។

ខ/- អ្នកមានសិទ្ធិបោះឆ្នោតជ្រើសតាំងសភាពាណិជ្ជកម្ម អាណត្តិបន្តបន្ទាប់ទៀត ត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម :

៤- មានសញ្ជាតិជាខ្មែរ

៥- មានអាយុយ៉ាងតិច ១៨ ឆ្នាំ

៦- ជាសមាជិករបស់សាមីសភាពាណិជ្ជកម្ម

**<u>មាត្រា ៩</u> :**

អ្នកមានសិទ្ធិបោះឆ្នោត ត្រូវសុំចុះឈ្មោះបោះឆ្នោត នៅក្នុងបញ្ជីអ្នកបោះឆ្នោតរបស់គណៈកម្មាការរៀបចំការបោះឆ្នោត តាមការកំណត់របស់គណៈកម្មាការនេះ ។

នៅក្រោយពេលបញ្ឈប់ការចុះឈ្មោះ បញ្ជីអ្នកបោះឆ្នោតត្រូវបិទផ្សាយនៅក្រសួងពាណិជ្ជកម្ម និងនៅសាលាខេត្ត-ក្រុង ។

ក្នុងករណីមានការតវ៉ា រាល់អ្នកមានសិទ្ធិបោះឆ្នោតអាចប្តឹងតវ៉ាមកគណៈកម្មាការក្នុងរយៈពេល ១៥ថ្ងៃយ៉ាងយូរ គិតពីថ្ងៃដែលបានបិទផ្សាយបញ្ជី ។

ហួសពីរយៈពេលនេះគណៈកម្មាការបោះឆ្នោតបញ្ចប់បញ្ជីជាស្ថាពរ ។ រាល់ការតវ៉ាត្រូវឈប់ទទួល ។

**<u>មាត្រា ១០</u> :**

ក/- បេក្ខជនសមាជិកជ្រើសតាំងសភាពាណិជ្ជកម្មអាណត្តិទី១ ត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម :

១- បានចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតរួចហើយ

២- មានអាយុយ៉ាងតិច ៣០ ឆ្នាំ

៣- បានបង់ថ្លៃសិទ្ធិឈរឈ្មោះបោះឆ្នោតតាមការកំណត់របស់គណៈកម្មការបោះឆ្នោត

៤- មិនបានប្រាសចាកសិទ្ធិខាងរដ្ឋប្បវេណី សិទ្ធិពលរដ្ឋ និងសិទ្ធិខាងនយោបាយ ។

ខ/- បេក្ខជនសមាជិកជ្រើសតាំងសភាពាណិជ្ជកម្មអាណត្តិបន្តបន្ទាប់ទៀតត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម :

១- បានចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតរួចហើយ

២- ជាសមាជិករបស់សាមីសភាពាណិជ្ជកម្ម និងជាក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម នៅក្រសួងពាណិជ្ជកម្ម និងបានបំពេញកាតព្វកិច្ចបង់ពន្ធជូនរដ្ឋត្រឹមត្រូវនៅឆ្នាំអាជីវកម្មកន្លងមក

៣- មានអាយុយ៉ាងតិច ៣០ ឆ្នាំ

៤- បានបង់ថ្លៃសិទ្ធិឈរឈ្មោះបោះឆ្នោតតាមការកំណត់របស់គណៈកម្មការបោះឆ្នោត

៥- មិនបានប្រាសចាកសិទ្ធិខាងរដ្ឋប្បវេណី សិទ្ធិពលរដ្ឋ និងសិទ្ធិខាងនយោបាយ ។

**មាត្រា ១១ :**

បេក្ខជនដែលចង់ឈរឈ្មោះជាសមាជិកជ្រើសតាំង ត្រូវសុំចុះឈ្មោះជាបេក្ខជនក្នុងបញ្ជីបេក្ខជនរបស់គណៈកម្មាការរៀបចំការបោះឆ្នោតតាមការកំណត់របស់គណៈកម្មាការនេះ ។ ការសុំចុះឈ្មោះនេះត្រូវធ្វើដោយសាមីបេក្ខជនផ្ទាល់ និង ចុះហត្ថលេខាដោយផ្ទាល់ដៃលើសំណុំបែបបទផ្សេងៗ ។

បញ្ជីបណ្តោះអាសន្ននៃបេក្ខជនត្រូវបញ្ឈប់១៥ថ្ងៃមុនថ្ងៃបោះឆ្នោត។ បញ្ជីនេះត្រូវបិទផ្សាយនៅក្រសួងពាណិជ្ជកម្ម និង នៅសាលាខេត្ត-ក្រុង ។ យ៉ាងយូរ ០៧ ថ្ងៃ មុនថ្ងៃបោះឆ្នោត បេក្ខជនមានសិទ្ធិតវ៉ាទៅរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម អំពីការរារាំងមិនអោយខ្លួនចុះឈ្មោះ ឬភ្លេចចុះឈ្មោះខ្លួននៅក្នុងបញ្ជីនេះ ។

បញ្ជីបេក្ខជនជាស្ថាពរត្រូវបញ្ចប់ ០៧ ថ្ងៃ មុនពេលបោះឆ្នោត ។ ចាប់ពីថ្ងៃបញ្ចប់តទៅមិនអនុញ្ញាតឱ្យធ្វើការតវ៉ាទេ ។ បញ្ជីស្ថាពរនេះត្រូវបិទផ្សាយនៅទីកន្លែងដែលបានបិទផ្សាយបញ្ជីបណ្តោះអាសន្ន ។

**មាត្រា ១២ :**

ការបោះឆ្នោតមានដំណើរប្រព្រឹត្តទៅដូចខាងក្រោម :

១- ការបោះឆ្នោតជ្រើសរើសសមាជិកជ្រើសតាំង របស់សភាពាណិជ្ជកម្ម ត្រូវបានអនុវត្តតាមគោលការណ៍ :

- យកសំលេងភាគច្រើន
- បោះឆ្នោតតាមឈ្មោះនីមួយៗ
- បោះឆ្នោតតែមួយជុំ

ក្នុងករណីដែលមានបេក្ខជនច្រើននាក់ទទួលសំលេងស្មើគ្នានោះ ត្រូវជ្រើសតាំងបេក្ខជនដែលមានអាយុច្រើនជាង ។

២- ការិយាល័យបោះឆ្នោតត្រូវបានរៀបចំតែមួយកន្លែង ហើយរយៈពេលបោះឆ្នោតត្រូវកំណត់តែមួយថ្ងៃ គឺចាប់ពីម៉ោង ៨:០០ ព្រឹកដល់ម៉ោង ១៥:០០ ល្ងាច ។

៣- ការឃោសនាបោះឆ្នោតជាសាធារណៈ ត្រូវកំណត់ចាប់ផ្តើម ១៥ ថ្ងៃ មុនថ្ងៃបោះឆ្នោតតាមប្រតិទិនរបស់គណៈកម្មាការរៀបចំការបោះឆ្នោត ហើយត្រូវបញ្ចប់ ៣ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

៤- អ្នកបោះឆ្នោត ត្រូវយកប័ណ្ណបោះឆ្នោតមកជាមួយសំរាប់ដូរយកសន្លឹកឆ្នោត។ អ្នកបោះឆ្នោតត្រូវមកបោះឆ្នោតដោយផ្ទាល់។ ប្រសិនបើមានការបាត់បង់ប័ណ្ណបោះឆ្នោត អ្នកបោះឆ្នោតត្រូវប្រកាសប្រាប់គណៈកម្មាការរៀបចំការបោះឆ្នោតជាលាយលក្ខណ៍អក្សរ ១ថ្ងៃ មុនថ្ងៃបោះឆ្នោត ដើម្បីសុំប្តូរយកប័ណ្ណបោះឆ្នោតថ្មី ។

៥-បេក្ខជននីមួយៗមានសិទ្ធិចាត់តាំងតំណាងម្នាក់ អោយចូលសង្កេតការណ៍ក្នុងកិច្ចដំណើរការកោះបោះឆ្នោតជាមួយគណៈកម្មាការ ។

៦- គណៈកម្មាការបោះឆ្នោត ត្រូវអញ្ជើញក្រសួង ស្ថាប័នពាក់ព័ន្ធមួយចំនួនអោយចូលរួមធ្វើជាអ្នកសង្កេតការណ៍ ។

៧- ការរាប់សន្លឹកឆ្នោតត្រូវរាប់អោយចប់នៅថ្ងៃបោះឆ្នោត ហើយយោងតាមកំណត់ហេតុនៃគណៈកម្មាការបោះឆ្នោត រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មត្រូវប្រកាសលទ្ធផលនៃការបោះឆ្នោតនៅថ្ងៃដដែល ។ លទ្ធផលនេះត្រូវចាត់ទុកជាស្ថាពរ ពុំអាចត្រូវបានតវ៉ានៅចំពោះមុខអង្គការណាបានឡើយ ។ ការទទួលស្គាល់សមាជិកជ្រើសតាំងរបស់

សភាពាណិជ្ជកម្ម ត្រូវធ្វើឡើងដោយអនុក្រឹត្យ ។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

**មាត្រា ១៣ :**

អនុក្រឹត្យលេខ ៦៣អនក្រ.បក ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ១៩៩៥ ស្តីពីរបៀបរបប និងការរៀបចំការបោះឆ្នោតសភាពាណិជ្ជកម្ម និងបទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនិងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ១៤ :**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័ន អភិបាលខេត្ត-ក្រុងពាក់ព័ន្ធ និងសភាពាណិជ្ជកម្ម ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១៤
- ឯកសារ-កាលប្បវត្តិ

# អនុក្រឹត្យ
# ស្តីពី
# ការបង្កើតសភាពាណិជ្ជកម្ម
# ខេត្ត សៀមរាប

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ២៦ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការបង្កើតសភាពាណិជ្ជកម្មខេត្តសៀមរាប

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលបានប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៣ ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសភាពាណិជ្ជកម្ម

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីរបៀបរបប និងការរៀបចំការបោះឆ្នោតសភាពាណិជ្ជកម្ម
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៤

## សម្រេច

**មាត្រា ១ :**

បង្កើតសភាពាណិជ្ជកម្មមួយសំរាប់ខេត្តសៀមរាប ហៅថាសភាពាណិជ្ជកម្មខេត្តសៀវរាប ព្រំដែនមណ្ឌលសភាពាណិជ្ជកម្មខេត្តសៀមរាប គឺកំណត់តាមព្រំដែនខេត្តសៀមរាប ។

**មាត្រា ២ :**

សភាពាណិជ្ជកម្មខេត្តសៀវរាប មានសមាជិកជ្រើសតាំងចំនួនដប់ប្រាំរូប (១៥រូប) ដែលជ្រើសរើសតាមការបោះឆ្នោត។ សភាពាណិជ្ជកម្មខេត្តសៀមរាប អាចបង្កើតគណៈកម្មាការផ្សេងៗតាមការ

ចាំបាច់ដើម្បីអភិវឌ្ឍប្រភេទអាជីវកម្មនីមួយៗ ។

**មាត្រា ៣ :**

តាមសំណើរបស់ប្រធានសភាពាណិជ្ជកម្មខេត្តសៀមរាប ក្រសួងពាណិជ្ជកម្មត្រូវកំណត់តាមប្រកាសនូវសមាជិកទីប្រឹក្សា ស្របតាមលក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា០៥នៃច្បាប់ស្តីពីសភាពាណិជ្ជកម្ម។

**មាត្រា ៤ :**

បទប្បញ្ញតិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥ :**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការក្រសួងស្ថាប័នពាក់ព័ន្ធ អភិបាលខេត្តសៀមរាប និងប្រធានសភាពាណិជ្ជកម្មខេត្តសៀមរាបត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

កន្លែងទទួលៈ

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- រាជកិច្ច
- ដូចមាត្រា ៥
- សាលាខេត្ត-ក្រុង
- ឯកសារ-កាលប្បវត្តិ

# ប្រកាស

# ស្តីពី

# ការបង្កើតគណកម្មការរៀបចំការ
# បោះឆ្នោតជ្រើសរើសសមាជិកជ្រើសតាំងនៃ
# សភាពាណិជ្ជកម្មខេត្ត-ក្រុង

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

Ministry of Commerce

No 168 MOC / M 2004

# ប្រកាស

## ស្តីពីការបង្កើតគណកម្មាការរៀបចំការបោះឆ្នោតជ្រើសរើស សមាជិកជ្រើសតាំង នៃសភាពាណិជ្ជកម្មខេត្ត-ក្រុង

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកប/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

- បានឃើញព្រះរាជក្រមលេខ នស/រកស/០៦៩៥/០៣ ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសភាពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ. បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក. ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីរបៀបរបប និងការរៀបចំការបោះឆ្នោតសភាពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ.បក. ២៣ អនក្រ.បក. ២៤ អនក្រ.បក. ២៥ អនក្រ.បក. ២៦ អនក្រ.បក. និង ២៧ អនក្រ.បក. ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការបង្កើតសភាពាណិជ្ជកម្មខេត្តកំពង់ចាម. បាត់ដំបង. បន្ទាយមានជ័យ. កោះកុង. សៀមរាប និងក្រុងសីហនុ
- យោងតាមការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## **សំ រេ ច**

**ប្រការ ១ :** បង្កើតគណកម្មាការរៀបចំការបោះឆ្នោតជ្រើសរើសសមាជិកជ្រើសតាំង នៃសភាពាណិជ្ជកម្មខេត្ត-ក្រុង ដែលមានសមាសភាពដូចខាងក្រោម :

១- ឯកឧត្តម **ម៉ៅ ថូរ៉ា** អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ជាប្រធាន

២- អ្នកឧកញ៉ា **សុខ គង់** ប្រធានសភាពាណិជ្ជកម្មរាជធានីភ្នំពេញ ជាអនុប្រធាន

៣- លោក **សម សម្បត្តិ** អគ្គនាយករងបច្ចេកទេសនៃក្រសួងពាណិជ្ជកម្ម ជាសមាជិក

៤- លោក **ប្រាក់ នគ** ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេសនៃក្រសួងពាណិជ្ជកម្ម ជាសមាជិក

៥- លោកឧកញ៉ា **ឈាង សុធី** អគ្គនាយកសភាពាណិជ្ជកម្មរាជធានីភ្នំពេញ ជាសមាជិក

៦- លោក លោកស្រី ប្រធានមន្ទីរពាណិជ្ជកម្មខេត្ត-ក្រុង ជាសមាជិក

៧- លោក **ហ៊ឹម ហារិន** អនុប្រធាននាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេសនៃក្រសួងពាណិជ្ជកម្ម ជាលេខាធិការ

៨- លោក **ឆន ទិរៈ** អនុប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស នៃក្រសួងពាណិជ្ជកម្ម ជាលេខាធិការ

**ប្រការ ២:** គណកម្មាការនេះ មានភារកិច្ចធ្វើសហប្រតិបត្តិការជាមួយគណកម្មាការរៀបចំការបោះឆ្នោតសភាពាណិជ្ជកម្ម នៅតាមខេត្ត-ក្រុងនីមួយៗក្នុងការចុះបញ្ជីអ្នកបោះឆ្នោតចុះបញ្ជីបេក្ខជនឈរឈ្មោះ និងរៀបចំការបោះឆ្នោតទៅតាមខ្លឹមសារទាំងឡាយ ដែលបានចែងអំពីភារកិច្ចរបស់គណកម្មាការនៅក្នុងជំពូក២ នៃអនុក្រឹត្យលេខ ៤២ អនក្រ. បក ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីរបៀបរបបនិងការរៀបចំការបោះឆ្នោតសភាពាណិជ្ជកម្ម ។

**ប្រការ ៣ :** បទបញ្ញត្តិទាំងឡាយ ដែលមានន័យផ្ទុយពីប្រការនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៤ :** អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេស នាយិកាខុទ្ទកាល័យ សភាពាណិជ្ជកម្មរាជធានីភ្នំពេញ និងសាមីខ្លួន ត្រូវអនុវត្តតាមប្រកាសនេះ អោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ. ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៤

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម-ប្រសិទ្ធ**

<u>កន្លែងទទួល</u>

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ហោ ណាំហុង
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- សាលាក្រុងភ្នំពេញ
- ដូចមាត្រា ៤ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**លេខ ០៥១ ពណ របចល**

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើមនិងបញ្ជូនមក**

**- ថ្នាក់ដឹកនាំមន្ទីរ "មេត្តាជ្រាប"**

**- ការិយាល័យរដ្ឋបាល-ហិរញ្ញវត្ថុ**

**- ការិយាល័យគ្រប់គ្រងអាជីវកម្មនិងតំលៃ**

**"ដើម្បីអនុវត្តន៍"**

**- ឯកសារ-កាលប្បវត្តន៍**

**សៀមរាប. ថ្ងៃទី ០៦ ខែ ៩ ឆ្នាំ ២០០៤**

**ជ.ប្រធានមន្ទីរពាណិជ្ជកម្មខេត្ត**

**ឃួន-ចន្ទសារិទ្ធ**

## ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីណែនាំ
# ស្តីពី

# បទបញ្ជាផ្ទៃក្នុងសភាពាណិជ្ជកម្ម
# ឆ្នាំ ២០០៣

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**KINDOM OF CAMBODIA**

**Nation – Religion – King**

ក្រសួងពាណិជ្ជកម្ម

Ministry of Commerce

No 202 MOC / M 2003

# សេចក្តីណែនាំ

# ស្តីពី

# បទបញ្ជាផ្ទៃក្នុងនៃសភាពាណិជ្ជកម្ម

**<u>ប្រការ ១</u> :** រចនាសម្ព័ន្ធសភាពាណិជ្ជកម្មមាន :

- សមាសភាពសមាជិកជ្រើសតាំង
- សមាជិកទីប្រឹក្សា
- ការិយាល័យប្រតិបត្តិ
- សន្និបាត
- គណៈកម្មការឯកទេស

***សមាសភាពសមាជិកជ្រើសតាំង និងសមាជិកទីប្រឹក្សា***

**<u>ប្រការ ២</u> :** សមាសភាពសភាពាណិជ្ជកម្ម មានសមាជិកជ្រើសតាំង និង សមាជិកទីប្រឹក្សា ។

**ប្រការ ៣** : សមាជិកជ្រើសតាំងត្រូវមានសញ្ជាតិខ្មែរ និង ជ្រើសរើសដោយការបោះឆ្នោតតាមនិតិវិធី កំណត់ដោយអនុក្រឹត្យស្តីពីរបៀបរបប និង ការរៀបចំការបោះឆ្នោតសភាពាណិជ្ជកម្ម ។
សមាជិកជ្រើសតាំង មានអាណត្តិ ០៦ឆ្នាំ ហើយអាចជ្រើសតាំងជាថ្មីទៀតបាន ។ ចំនួនសមាជិកជ្រើសតាំង ត្រូវកំណត់នៅក្នុងអនុក្រឹត្យបង្កើតសភាពាណិជ្ជកម្មនិមួយៗ ។
ក្នុងករណីមាន សមាជិកជ្រើសតាំងណាម្នាក់ លាលែងពីតំណែងសមាជិកនោះ ត្រូវធ្វើសំណើលាលែង តាមរយៈប្រធានសភាពាណិជ្ជកម្មទៅ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។ រាល់សមាជិកជ្រើសតាំង និងទីប្រឹក្សាសភាពាណិជ្ជកម្ម ដែលមិនបានចូលរួមក្នុងសន្និបាត សម័យប្រជុំ ៣ខែម្តង ចំនួន ២ដង បន្តបន្ទាប់ដោយគ្មានមូលហេតុសមស្រប ត្រូវចាត់ទុកថាបានលាលែង ចេញពីសភាដោយប្រកាសរបស់ក្រសួងពាណិជ្ជកម្ម តាមសំណើរបស់ប្រធានសភាពាណិជ្ជកម្ម ។

**ប្រការ ៤** : សមាជិកទីប្រឹក្សាបានតែងតាំង ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម តាមសំណើរបស់ប្រធានសភាពាណិជ្ជកម្មដែលជ្រើសរើសក្នុងចំណោម តំណាងម្ចាស់សហគ្រាស តំណាងសមាគមអាជីវកម្ម តំណាងក្របខ័ណ្ឌដឹកនាំរបស់សហគ្រាស និង តំណាងបុគ្គលិកសហគ្រាស តាមបញ្ជីកំណត់របស់ក្រសួងពាណិជ្ជកម្ម ។ ចំនួនសមាជិកទីប្រឹក្សាមិនអាចលើសពីចំនួនសមាជិកជ្រើសតាំងបានឡើយ ។

**ប្រការ ៥** ៖ អាណត្តិសមាជិកទីប្រឹក្សាមានរយៈពេល ០៦ ឆ្នាំ ប៉ុន្តែអាចត្រូវជ្រើសរើសអោយបន្តភារកិច្ចជាថ្មីទៀត ក្នុងករណីចាំបាច់ ។ សមាជិកជ្រើសតាំងមានកាតព្វកិច្ច បង់ថវិកាទ្រទ្រង់សភាប្រចាំខែនៅរៀលរាល់ ២សប្តាហ៍ដើមខែជាទៀតទាត់ និង ស្មើៗគ្នាទៅតាមការកំណត់របស់មហាសន្និបាត ។ ករណីសមាជិកជ្រើសតាំងណាមិនបានបង់ថវិកាទ្រទ្រង់សភាចំនួន០៦ខែ សមាជិកនោះត្រូវបាត់បង់ សមាជិកភាពដោយស្វ័យប្រវត្តិ ។ ដោយឡែកសមាជិកទីប្រឹក្សាអាចបង់ថវិកាទ្រទ្រង់សភាទៅតាមការស្ម័គ្រចិត្ត

## ការិយាល័យប្រតិបត្តិ

**ប្រការ ៦** ៖ សភាពាណិជ្ជកម្មស្ថិតនៅក្រោម ការគ្រប់គ្រងរបស់ការិយាល័យប្រតិបត្តិមួយ ។ សមាជិកការិយាល័យប្រតិបត្តិ ត្រូវជ្រើសរើសដោយសមាជិកជ្រើសតាំង តាមរយៈការបោះឆ្នោតក្នុងចំណោមសមាជិកជ្រើសតាំង ។

**ប្រការ ៧** ៖ សាមាជិកការិយាល័យប្រតិបត្តិមាន ប្រធានដែលជាប្រធានសភាពាណិជ្ជកម្ម អមដោយអនុប្រធានម្នាក់ ឬ ច្រើននាក់ ហិរញ្ញិកម្នាក់ ៗ ច្រើននាក់ និង លេខាធិការមួយចំនួន ។ ចំនួនសមាជិកជាក់ស្តែងត្រូវបានកំណត់ដោយ ក្រុមសមាជិកជ្រើសតាំងតាមទំហំការងារ ។ អាណត្តិរបស់សមាជិកការិយាល័យប្រតិបត្តិមានរយៈពេល ០៣ឆ្នាំ ។

**ប្រការ ៨** : ការបោះឆ្នោតរើស ប្រធានសភាពាណិជ្ជកម្ម ត្រូវធ្វើឡើងជា ០២ជុំ បើជុំទីមួយ ពុំបានផ្តល់ចំនួនសំលេងដាច់ខាតដល់បេក្ខជនណាមួយទេ បេក្ខជនដែលមានសិទ្ធិ អោយគេជ្រើសរើសនៅជុំទីពីរមានចំនួនតែ០២នាក់ប៉ុណ្ណោះក្នុងចំណោមបេក្ខជន ដែលបានទទួលសំលេងឆ្នោតលើសគេនៅជុំទីមួយ ។ បើសិនការបោះឆ្នោតនៅជុំទី២ បេក្ខជនទាំង២ បានទទួលសម្លេងស្មើគ្នា ការបោះឆ្នោតជ្រើសរើសប្រធាន ត្រូវលើកយកទៅធ្វើនៅថ្ងៃបន្ទាប់ជាថ្មីទៀត ។ ចំពោះការបោះឆ្នោតរើសអនុប្រធាន ការបោះឆ្នោតរើសហិរញ្ញឹក និង ក្រុមលេខាធិការ ត្រូវធ្វើឡើងតែមួយជុំដោយយកសំលេងភាគច្រើនមិនដាច់ខាត ។ ក្នុងករណីមានសំលេងស្មើគ្នាត្រូវជ្រើសតាំងអ្នកដែលមានអាយុច្រើនជាង ។

**ប្រការ ៩** : សមាជិកជ្រើសតាំងចំនួនពាក់កណ្តាលយ៉ាងតិច អាចស្នើសុំអោយរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មរៀបចំបោះឆ្នោត ដើម្បីដកតំណែងពីប្រធានសភាពាណិជ្ជកម្ម ។ ការដកតំណែងនេះនឹងត្រូវសំរេចបានលុះត្រាតែ មានសំលេងយល់ព្រមដកចំនួន ២/៣ នៃចំនួនសមាជិកជ្រើសតាំងទាំងអស់ ។

សមាជិកជ្រើសតាំង ដែលមានអាយុច្រើនជាងគេ ត្រូវបានជ្រើសរើសអោយធ្វើជាប្រធានបណ្តោះអាសន្ន រហូតដល់ការបោះឆ្នោតចប់សព្វគ្រប់ និង តែងតាំងប្រធានពេញសិទ្ធិ ។

**ប្រការ ១០** ៖ សមាជិកដែលជាប់រវល់ អាចប្រគល់សិទ្ធិជាលាយលក្ខអក្សរដល់សមាជិកផ្សេងទៀតក្នុងការិយាល័យប្រតិបត្តិអោយបោះឆ្នោតជំនួសខ្លួនបាន ។ ប៉ុន្តែសមាជិកម្នាក់ អាចទទួលលិខិតប្រគល់សិទ្ធិបានតែមួយទេ ។

**ប្រការ ១១** ៖ នៅពេលដែលសមាជិក ក្នុងការិយាល័យប្រតិបត្តិស្លាប់ ឬលាលែង សភាត្រូវជ្រើសតាំងសមាជិកជំនួសវិញតាមបែបបទដែលបានគ្រោងទុក ដើម្បីបញ្ចប់អាណត្តិធម្មតា របស់ការិយាល័យ ។

**ប្រការ ១២** ៖ ករណីមានសមាជិកជ្រើសតាំង ឬ សមាជិកទីប្រឹក្សាណាមានទោសទណ្ឌដោយប្រការណាមួយ សមាជិករូបនោះត្រូវបាត់បង់សមាជិកភាពរបស់ខ្លួនដោយស្វ័យប្រវត្តិ ។

**ប្រការ ១៣** ៖ ដំណើរការរបស់ការិយាល័យប្រតិបត្តិ ៖
ការិយាល័យប្រតិបត្តិ បើកសម័យប្រជុំមួយខែម្តង ឬ នៅពេលដែលប្រធានយល់ថាចាំបាច់ ។ ប្រធានសភាត្រូវធ្វើជាអធិបតីរាល់សម័យប្រជុំឬប្រគល់សិទ្ធិជូនអនុប្រធានណាម្នាក់ក្នុងករណីខកខានប្រធានសភាអាចអញ្ជើញប្រធានគណៈកម្មការផ្សេងៗ ឬ ជនឯទៀតអោយចូលរួមប្រជុំបាន ។

**ប្រការ ១៤** : ភារកិច្ចរបស់ប្រធានសភាពាណិជ្ជកម្ម :

- ប្រធានសភាពាណិជ្ជកម្ម ជាតំណាងសភាចំពោះមុខអាជ្ញាធរ និង តតិយជន
- អនុវត្តរាល់ភារកិច្ចដែលមានចែងក្នុងមាត្រា ៩ នៃច្បាប់ស្តីពីសភាពាណិជ្ជកម្ម
- អនុវត្តរាល់សេចក្តីសំរេចរបស់អង្គប្រជុំ របស់ការិយាល័យប្រតិបត្តិ និង សន្និបាត
- ប្រធានសភាជាហត្ថលេខី ក្នុងកិច្ចសន្យា ដែលសភាពាណិជ្ជកម្មជាភាគីដឹកនាំការិយាល័យផ្ទាល់ ។ ក្នុងការបំពេញការងារ ប្រធានអាចប្រគល់សិទ្ធិ អោយសមាជិកណាមួយបំពេញការងារជំនួសបាន ។
- គ្រប់គ្រងគណៈកម្មការឯកទេស
- ណែនាំអង្គភាពអាជីវកម្មរបស់សភាពាណិជ្ជកម្ម
- តែងតាំង និងគ្រប់គ្រងបុគ្គលិកផ្ទាល់របស់សភាពាណិជ្ជកម្ម
- សំរេចរាល់ការចំណាយរបស់សភាពាណិជ្ជកម្មតាមការកំណត់របស់សន្និបាត
- តែងតាំង និងដកហូតអគ្គនាយកផ្ទាល់ និង កំណត់ភារកិច្ចរបស់អគ្គនាយក

**ប្រការ ១៥** : អគ្គនាយកមានភារកិច្ចគ្រប់គ្រង ផ្នែកបច្ចេកទេសរបស់គណៈកម្មការឯកទេស និង អង្គភាពអាជីវកម្មទាំងអស់របស់សភាពាណិជ្ជកម្ម ។

## ***សន្និបាតសភាពាណិជ្ជកម្ម***

**<u>ប្រការ ១៦</u> :** សមាសភាពសន្និបាត

សមាសភាពរបស់សន្និបាតមាន : សមាជិកជ្រើសតាំងទាំងអស់ សមាជិកទីប្រឹក្សា ព្រមទាំងតំណាងរដ្ឋាភិបាល (តំណាងក្រសួងពាណិជ្ជកម្មម្នាក់ និង តំណាងអភិបាលខេត្ត ក្រុងម្នាក់) ។ សមាជិកផ្សេងទៀត អាចចូលរួមដើម្បីបំភ្លឺសន្និបាតលើបញ្ហាអ្វីមួយ បើមានការអញ្ជើញពីប្រធានសភា ។ សមាជិកទីប្រឹក្សា និង តំណាងរដ្ឋាភិបាល ដែលចូលរួមក្នុងសន្និបាតមានត្រឹមតែសំលេងផ្តល់យោបល់ប៉ុណ្ណោះ ។

**<u>ប្រការ ១៧</u> :** សន្និបាតមានភារកិច្ចដូចតទៅ :

- ពិនិត្យ និង អនុម័តថវិកាប្រចាំឆ្នាំ របស់សភាពាណិជ្ជកម្ម
- សំរេចរាល់បញ្ហាដែលជាផលប្រយោជន៍រួមទាក់ទិនដល់អាជីវកម្មណាមួយ
- កំណត់ទិសដៅសកម្មភាព និង ទិសដៅសេដ្ឋកិច្ចរបស់សភា ប្រធានសភាពាណិជ្ជកម្មទទួលបន្ទុកអនុវត្តរាល់សេចក្តីសំរេចរបស់សន្និបាត ។

**<u>ប្រការ ១៨</u> :** របៀបប្រជុំសន្និបាត

- សន្និបាតត្រូវបើកសម័យប្រជុំ៣ខែម្តងយ៉ាងតិច ។ បើមានការចាំបាច់ប្រធានសភាអាចស្នើប្រជុំសន្និបាតបន្ថែមទៀត ។

- អង្គសន្និបាតត្រូវដឹកនាំដោយ ប្រធានសភាពាណិជ្ជកម្ម ឬ អនុប្រធាន ក្នុងករណីប្រធានអវត្តមាន ។ ក្នុងករណីអវត្តមានទាំងពីរនាក់ ប្រធានមានចាត់តាំងតំណាងអោយដឹកនាំអង្គប្រជុំ ។
- ប្រធានសភាត្រូវផ្តល់ជូនដល់សមាជិកទាំងអស់នូវរបៀបវារអោយបាន ០៧ថ្ងៃ មុនបើកសន្និបាត ។
- សមាជិកជ្រើសតាំង និង សមាជិកទីប្រឹក្សា អាចស្នើកម្មវត្ថុក្រៅពីកម្មវត្ថុដែលមានចែងក្នុងប្រការ ១៧ ខាងលើ បញ្ចូលក្នុងរបៀបវារៈតាមការយល់ព្រមពីប្រធាន ។
- ប្រធានអង្គសន្និបាតជាអ្នកកំណត់វិន័យ និង សេចក្តីរៀបរយនៅពេលប្រជុំសន្និបាតម្តងៗ ហើយជាអ្នកជ្រើសរើសលេខាធិការអចិន្ត្រៃយ៍របស់សន្និបាត ។
- សមាជិកជ្រើសតាំង និង ទីប្រឹក្សាណាដែលមានធុរៈ រួចពុំអាចចូលរួមប្រជុំសន្និបាតបានត្រូវសុំច្បាប់ជាលាយល័ក្ខអក្សរមកប្រធានសភាមុនថ្ងៃកំណត់ប្រជុំយ៉ាងតិចចំនួន២ថ្ងៃ ។
- ការបញ្ចេញមតិ សមាជិកអង្គសន្និបាតត្រូវលើកដៃសុំការអនុញ្ញាតអំពីប្រធាន នៃអង្គសន្និបាត រួចត្រូវនិយាយអោយបានចំខ្លឹមសារនៃកម្មវត្ថុដែលត្រូវពិភាក្សា ។
- កូរ៉ុមរបស់សន្និបាតតំរូវអោយមានវត្តមាន ចំនួនពាក់កណ្តាលនៃចំនួនសមាជិកជ្រើសតាំង ។ បើកូរ៉ុមនេះមិនគ្រប់តាមការកំណត់ខាងលើទេ ប្រធានសភាត្រូវកោះប្រជុំជាលើកទីពីរនៅរយះពេល ០៧ថ្ងៃក្រោយ ហើយកូរ៉ុមថ្មីដែលត្រូវកណត់

យកពី ១/៣ នៃចំនួនសមាជិកសន្និបាតទាំងអស់ ក្នុងនោះត្រូវមានវត្តមាន ១/៣ នៃចំនួនសមាជិកជ្រើសតាំង ។

**<u>ប្រការ ១៩</u> :** សេចក្តីសំរេចរបស់សន្និបាត :

- សេចក្តីសំរេចរបស់សន្និបាត ត្រូវយកតាមសំលេងភាគច្រើននៃសមាជិកវត្តមាន ។ ក្នុងករណីមានសំលេងស្មើគ្នា សំលេងខាងប្រធានចាត់ទុកជាបានការ ។
- ការផ្សព្វផ្សាយពតិមានស្តីពីសន្និបាត ត្រូវមានការអនុញ្ញាតពីប្រធានសភាពាណិជ្ជកម្ម ។

## *គណៈកម្មការឯកទេស និង អគ្គនាយកអាជីវកម្ម*

**<u>ប្រការ ២០</u> :** គណៈកម្មការឯកទេស :

ដើម្បីជួយប្រធានក្នុងការបំពេញការងារ សភាពាណិជ្ជកម្មអាចមានគណៈកម្មការឯកទេសមួយចំនួន ។

ភារកិច្ច និង សមាសភាពរបស់គណៈកម្មការឯកទេសនិមួយៗ ត្រូវកំណត់ដោយសន្និបាតតាមសំណើរបស់ប្រធានសភា ។

គណៈកម្មការនិមួយៗត្រូវដឹកនាំដោយសមាជិកជ្រើសតាំងម្នាក់ ។

គណៈកម្មការនិមួយៗ ត្រូវមានសមាជិកយ៉ាងតិច ០២នាក់ ដែលចេញពីប្រភេទវិជ្ជាជីវៈផ្សេងៗគ្នា ។ សមាជិកទីប្រឹក្សាអាចតែងតាំងជាសមាជិកគណៈកម្មការឯកទេស ។

សមាជិកគណៈកម្មការ ត្រូវចូលរួមប្រជុំតាម ការកំណត់របស់

ប្រធានគណៈកម្មការ ។ សេចក្តីអនុម័ត និង របាយការណ៍ផ្សេងៗ ត្រូវបញ្ជូនទៅប្រធានសភាតាមរយៈអគ្គនាយក ។

**ប្រការ ២១** : អង្គភាពអាជីវកម្ម :

យោងតាមប្រការ ១១-១២ និង ១៣ នៃច្បាប់ស្តីពីសភាពាណិជ្ជកម្ម ដែលផ្តល់លទ្ធភាពអោយសភាពាណិជ្ជកម្មប្រកបអាជីវកម្ម សភាពាណិជ្ជកម្មអាចបង្កើតអង្គភាពអាជីវកម្មមួយចំនួន ដើម្បីរកចំណូលផ្ទាល់សំរាប់សភា ។

អង្គភាពអាជីវកម្មនិមួយៗ ត្រូវស្ថិតនៅក្រោមការដឹកនាំរបស់នាយកម្នាក់តែងតាំងដោយប្រធាន ។ បុគ្គលិកបំរើការអង្គភាពអាជីវកម្មពុំអាចប្រកបការងារ ឬ ប្រកបអាជីវកម្មផ្សេងទៀតបានឡើយ ។

## ***ហិរញ្ញវត្ថុ***

**ប្រការ ២២** : ទុនអាជីវកម្ម :

យោងមាត្រា ១៦-១៧-១៨ និង ១៩ នៃច្បាប់ស្តីពីសភាពាណិជ្ជកម្ម សភាពាណិជ្ជកម្មអាចខ្ចីប្រាក់ :

- ធនាគារក្នុងស្រុក ដោយផ្អែកតាមគំរោងបទដ្ឋានសេដ្ឋកិច្ច បច្ចេកទេស និងទំហំអាជីវកម្ម
- ធនាគារក្រៅប្រទេស ឬ ស្ថាប័នហិរញ្ញវត្ថុនានាត្រូវឡើងគំរោងអោយបានត្រឹមត្រូវហើយលើកសំណើសុំការអនុញ្ញាត

ពីក្រសួងពាណិជ្ជកម្ម ។

- គ្រប់ប្រាក់កម្ចីទាំងអស់ត្រូវដាក់ឆ្លងការអនុម័តពីសន្និបាតមុន នឹងខ្ចីចងការប្រាក់ពីធនាគារ ឬ ស្ថាប័នហិរញ្ញវត្ថុ

**<u>ប្រការ ២៣</u> :** ប្រធានសភាពាណិជ្ជកម្ម ជាអ្នកចេញបញ្ជាចំណាយរបស់សភា ។

ប្រធានសភាអាចផ្ទេរអំណាច ចេញបញ្ជាចំណាយទៅអោយអនុប្រធានការិយាល័យប្រតិបត្តិណាម្នាក់ក្នុងពេលអវត្តមានរយៈពេលយូរ ។ ចំពោះចំណាយ ឬ ចំណូលប្រចាំថ្ងៃប្រធានសភាអាចផ្ទេរសិទ្ធិអោយអគ្គនាយកជាអ្នកបញ្ជាចំណាយទាំងនេះ ដោយមានបញ្ជាក់ផងដែរនូវចំនួនទឹកប្រាក់អតិបរិមា ។

**<u>ប្រការ ២៤</u> :** ហិរញ្ញិកជាអ្នកទូទាត់ចំណាយ និង ជាអ្នកគ្រប់គ្រងមូលនិធិសភា ។ ក្នុងករណីអវត្តមានហិរញ្ញិក អាចផ្ទេរសិទ្ធិអោយហិរញ្ញិករងជំនួស ។ ហិរញ្ញិកជាអ្នករៀបចំ តុល្យការប្រចាំឆ្នាំ និង គំរោងថវិកាឆ្នាំបន្ទាប់ ដើម្បីដាក់ជូនការិយាល័យប្រតិបត្តិពិនិត្យ និង បញ្ជូនទៅសុំការអនុម័តពីសន្និបាត ។

គំរោងចំណូល ចំណាយ ថវិកាប្រចាំឆ្នាំ និង របាយការណ៍ទូទាត់ថវិកាប្រចាំឆ្នាំ ត្រូវផ្ញើជូនក្រសួងពាណិជ្ជកម្មមួយច្បាប់ ដើម្បីជាពតិមាន ។

**ប្រការ ២៥** : បទបញ្ជាផ្ទៃក្នុងនេះ មានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ ២៦** : បទបញ្ជាទាំងឡាយណា ដែលផ្ទុយនឹងបទបញ្ជានេះ ត្រូវចាត់ទុកជានិរាករណ៍ ។

រាជធានីភ្នំពេញ. ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៣

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ~ ប្រសិទ្ធ**